


# ពូជស្រូវកណ្តាល "ខា ៣"

ពូជស្រូវ **"ខា ៣"** ជាពូជស្រូវកណ្តាលដែលបានធ្វើការរំដោះ និងផ្សព្វផ្សាយដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៏កសិកម្មកម្ពុជានាឆ្នាំ ១៩៩៥។ បច្ចុប្បន្នពូជស្រូវកណ្តាលបាន និងកំពុងពេញនិយមក្នុងចំណោមប្រជាកសិករនៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយពូជស្រូវនេះផ្តល់នូវទិន្នផលខ្ពស់ និងបាយទន់ឆ្ងាញ់។

## លក្ខណៈពិសេសៗរបស់ពូជស្រូវ "ខា ៣"



ពូជស្រូវ **"ខា ៣"** ជាពូជស្រូវដែលមានវេទរសភាពនឹងរយៈពន្លឺ (ប្រកាន់រដូវ) និងចាប់ចេញផ្កាក្នុងកំឡុងថ្ងៃទី ៣០ ខែតុលា ទៅដល់ថ្ងៃទី ០៧ ខែវិច្ឆិកា អាស្រ័យទៅលើអាកាសធាតុ និងពេលវេលាដាំដុះ។ កំពស់ដើមរបស់ពូជ **"ខា ៣"** ប្រែប្រួលពី ១២០-១៧០ ស.ម និងចំនួនដើមបែកផ្តល់ផល គឺចាប់ពី ៧-១០ ដើម ក្នុងមួយគុម្ព អាស្រ័យទៅតាមប្រភេទដី។ ចំនួនគ្រាប់ក្នុងមួយកួរមានចាប់ពី ១០០-១៥០ គ្រាប់ និងមានប្រវែងកួរ ២០-២៥ ស.ម។ រីឯទិន្នផលរបស់វាវិញ គឺអាចទទួលបានចាប់ពី ២,៥ តោន ទៅ ៤,៥ តោនក្នុងផ្ទៃដី ១ ហិកតា។ ពូជស្រូវ "ខា ៣" គឺជាពូជដែលធន់ទ្រាំមធ្យមទៅនឹងភាពរាំងស្ងួត តែមិនធន់ទៅនឹងមមាចត្នោតទេ។

## វិធីសាស្ត្រដាំដុះ

សម្រាប់ស្រូវសន្ទូង ចំពោះតំបន់ដែលងាយរងគ្រោះរាំងស្ងួត និងទឹកជំនន់ បរិមាណគ្រាប់ពូជដែលប្រើប្រាស់គឺពី ៦០-៨០ គីឡូក្រាមក្នុងមួយហិកតា។ ចំពោះតំបន់ដែលគ្រប់គ្រងទឹកបាន បរិមាណគ្រាប់ពូជដែលប្រើប្រាស់គឺពី ៣០-៤០ គីឡូក្រាមក្នុងមួយហិកតា។ ក្នុងករណីដែលគ្រាប់ពូជសុទ្ធ និងមានសុខភាពល្អ ព្រមទាំងគ្រប់គ្រងទឹកបាន និងថែទាំបានល្អ បរិមាណគ្រាប់ពូជដែលត្រូវការក្នុងមួយហិកតាគឺពី ១៥-២០ គីឡូក្រាម។ ដើម្បីឱ្យសំណាបដុះលូតលាស់ធំធាត់ល្អ គេត្រូវសាបគ្រាប់ពូជមួយគីឡូក្រាមលើផ្ទៃដីថ្នាល ១០ ម៉ែត្រការ៉េ។ ទីសំណាបត្រូវធ្វើនៅជិតប្រភពទឹក តែត្រូវឆ្ងាយពីម្លប់ព្រៃ ឬកន្លែងមានភ្លើងអគ្គីសនី ដើម្បីជៀសវាងការបំផ្លាញពីសត្វល្អិតចង្រៃ។ ជាការល្អ គួរស្ទូងសំណាបដែលមានអាយុ ២៥-៣០ ថ្ងៃ ហើយក្នុងមួយគុម្ពចំនួន ២-៣ ដើម។ សម្រាប់ស្រូវពង្រួស ចំពោះតំបន់ដែលងាយរងគ្រោះរាំងស្ងួត និងទឹកជំនន់ បរិមាណគ្រាប់ពូជដែលប្រើប្រាស់គឺពី ១០០-១៥០ គីឡូក្រាមក្នុងមួយហិកតា។ ចំពោះតំបន់ដែលគ្រប់គ្រងទឹកបាន និងគ្រាប់ពូជសុទ្ធល្អ បរិមាណគ្រាប់ពូជដែលប្រើប្រាស់គឺពី ៧០-៨០ គីឡូក្រាមក្នុងមួយហិកតា។ គួររៀបចំដីឱ្យបានល្អ និងរាបស្មើមុនស្ទូង ឬព្រួស។ ការភ្ជួររាស់គួរតែធ្វើឱ្យបាន ២-៣ សារជាការល្អប្រសើរ។ បើសិនស្រែអាចបញ្ចេញបញ្ចូលទឹកបានបន្ទាប់ពីស្ទូង ឬព្រួសបាន ២០ ថ្ងៃអាចបញ្ចេញទឹកឱ្យអស់ពីក្នុងស្រែ ២-៤ ថ្ងៃរួចបញ្ចូលទឹកថ្មីវិញ។ ធ្វើរបៀបនេះ គឺដើម្បីធ្វើឱ្យស្រូវកាន់តែបែកគុម្ពល្អ។ ប៉ុន្តែពេលស្រូវបែក គុម្ពអតិបរិមាគួរបង្ហូរទឹករយៈពេលមួយអាទិត្យ ដើម្បីកុំឱ្យស្រូវដុះខ្នែងមកច្រើនទៀត។

## ការប្រើប្រាស់ជី

ការប្រើប្រាស់ជីសមស្របតាមកម្រិតណែនាំ នឹងមិនបណ្តាលអោយមានការថយចុះ ឬបាត់បង់ក្លិន ឬគុណភាពដទៃទៀតឡើយ។ គួរដាក់ជី ២-៣ ដងក្នុង ១ វដ្តជីវិតរបស់ស្រូវដោយៈ

- *បាចលើកទី១:* ទ្រាប់បាតមុនពេលស្ទូង ប្រើជីធម្មជាតិពី ៥-១០ តោន/ហត និងរួមផ្សំជាមួយជីគីមីដូចមានក្នុងតារាងទី ១។ សម្រាប់ពេលវេលានៃការបាចជីបំប៉នលើកទីមួយ និងលើកទីពីរធ្វើឡើងទៅតាមពេលវេលាសាបដូចមានបង្ហាញនៅក្នុងតារាងទី ២។



**តារាងទី ១**

| ប្រភេទដី | ប្រភេទជី | ទ្រាប់បាត | បំប៉ន (គក្រ/ហត) | |
|---|---|---|---|---|
| | | (គក្រ/ហត) | លើកទី១ | លើកទី២ |
| ដីខ្សាច់ (ដីព្រៃខ្មែរ ប្រទះឡាង) | អ៊ុយរ៉េ | ១៦ | ៣៥ | ២៦ |
| | ដេអាប៉េ | ២៦ | ០ | ០ |
| | ប៉ូតាស | ១០០ | ០ | ០ |
| ដីល្បាយឥដ្ឋ (ដីបាកាន អូរូង ទួលសំរោង គោកត្រប់ ក្រគរ ) | អ៊ុយរ៉េ | ២៧ | ១០៥ | ៦០ |
| | ដេអាប៉េ | ៥៥ | ០ | ០ |
| ដីឥដ្ឋ (ដីកំពង់សៀម ក្បាលពោធិ កៀនស្វាយ ) | អ៊ុយរ៉េ | ៥០ | ៧០ | ៥៣ |
| | ដេអាប៉េ | ០ | ០ | ០ |

**តារាងទី ២**

| ពេលវេលាសាប | បំប៉នលើកទីមួយ | បំប៉នលើកទីពីរ |
|---|---|---|
| ១-៣១ មិថុនា | ៣០ថ្ងៃ ក្រោយស្ទូង | ២៦-២៩ កញ្ញា |
| ១-១៥ កក្កដា | ៣០ថ្ងៃ ក្រោយស្ទូង | ៣០ កញ្ញា -២ តុលា |
| ១៦-៣០ កក្កដា | ៣០ថ្ងៃ ក្រោយស្ទូង | ៣ -៦ តុលា |

## ការប្រមូលផល និងទុកដាក់

- ត្រូវធ្វើការច្រូតកាត់នៅរវាង ៣០-៣៥ ថ្ងៃ បន្ទាប់ពីស្រូវហាលផ្កាស្រុះ ឬពេលដែលប្រមាណ ៨៥ ភាគរយនៃគ្រាប់ស្រូវទុំ។
- ត្រូវហាល ២-៣ ថ្ងៃ ដើម្បីបន្ថយសំណើមនៅក្នុងគ្រាប់ឱ្យនៅ ១៤ ភាគរយ មុននឹងទុកជាការល្អ។ សូមយកគ្រាប់ស្រូវមកខាំដើម្បីកំណត់ បើគ្រាប់ស្រូវនោះបាក់ គឺមានន័យថាគ្រាប់ស្រូវស្ងួតល្អអាចទុកដាក់បាន។
- គ្រាប់ពូជ ត្រូវច្រកទុកនៅក្នុងបាវក្រចៅដាច់ដោយឡែកពីគ្រាប់ស្រូវចំណី នៅកន្លែងដែលស្ងួតល្អ ហើយគ្មានការបំផ្លាញពីសត្វកណ្តុរ មាន់ ទា ជាដើម។ ត្រូវសរសេរឈ្មោះពូជ និងថ្ងៃខែច្រូតកាត់ដាក់នៅលើបាវឱ្យបានត្រឹមត្រូវល្អ។
- គ្រាប់ស្រូវចំណីត្រូវទុកដាក់ក្នុងជង្រុកឱ្យបានល្អ ដោយការពារកុំឱ្យសត្វកណ្តុរ មាន់ ទា ចូលស៊ី និងមិនឱ្យទទឹក។




សំរាប់ព័ត៌មានបន្ថែមសូមធ្វើការទាក់ទង ការិយាល័យរុក្ខជម្រើសវិទ្យា មជ្ឈមណ្ឌលបណ្តុះបណ្តាល និងព័ត៌មាន ការិយាល័យផែនការ សហប្រតិបត្តិការ និងពាណិជ្ជកម្ម នៃវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា នៅតាមបណ្តោយផ្លូវជាតិលេខ៣ សង្កាត់ប្រទះឡាង ខ័ណ្ឌដង្កោ ភ្នំពេញ ឬតាមប្រអប់សំបុត្រលេខ០១ ភ្នំពេញ, ទូរស័ព្ទលេខ: (៨៥៥-២៣)២១៩ ៦៩៣-៤
ទូរសារលេខ: (៨៥៥-២៣ ) ២១៩ ៨០០ ទូរអក្សរ: cardi@cardi.org.kh វែបសាយ: www.cardi.org.kh
PBREED@cardi.org.kh TRIN@cardi.org.kh HUNYADANA@cardi.org.kh